ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

បនដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការទុកដាក់ស្រូវ




រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ នាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម



ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី

អ្នកសរសេរ :   មាស ពិសិដ្ឋ
និស្សិតបណ្ឌិតសិក្សា នៅសាកលវិទ្យាល័យម៉ាស្សី
ប្រទេសញូវហ្សេឡែន

កាលបរិច្ឆេទ : ខែ វិច្ឆិកា ឆ្នាំ ២០០៥

## សេចក្ដីផ្ដើម

ពាក្យពេញនៃ **បអប** គឺ "បទដ្ឋានអនុវត្តបច្ចេកវិជ្ជា" ។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិជ្ជាដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់ឱ្យមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិជ្ជានេះទៅកសិករ ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុកនិងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាលនិងផ្នែក ផ្សេងៗ ទៀតដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៍ កសិកម្មនៅតាមមូលដ្ឋានប្រើប្រាស់ ។ បអប មានលក្ខណៈ ដូចខាងក្រោមនេះ :-

- អាចបត់បែនបាន -បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្ដល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករតាមរយៈប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗ របស់កសិករ ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធ កសិត្រ - បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប មាននៅតាមស្ថាប័ន នានាដូចខាងក្រោមៈ

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេ សាទ ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រ កម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេក វិជ្ជា ។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យ របស់ក្រុមការងារ បអប បន្ទាប់មកអនុម័តនិងអនុញ្ញាតិដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ សម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងៈ**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# មាតិកា


សេចក្តីផ្តើម ...........

មាតិកា ...........

១. ការពិពណ៌នា ...........១

១.១ គោលបំណង និង សារៈប្រយោជន៍ ...........១

១.២ លក្ខណៈវិនិច្ឆ័យអំពីភាពសមស្របខាងផ្នែកបច្ចេកទេស ...........១

១.២.១ យេនឌ័រ ...........១

១.២.២ លក្ខខ័ណ្ឌ ឬ ស្ថានភាពភូមិសាស្ត្រ ...........២

១.២.៣ សេចក្តីត្រូវការពលកម្ម ...........២

១.២.៤ ស្ថានភាពសេដ្ឋកិច្ចរបស់កសិករដែលបានទទួលយកនូវបច្ចេកវិទ្យានេះ ... ២

១.២.៥ អនុសាសន៍ និង តម្រូវការពិសេសនានាផ្សេងទៀត ...........២

២. គោលការណ៍ណែនាំបច្ចេកទេស ...........៣

២.១ មូលហេតុ ឬ ភាពចាំបាច់ក្នុងការបង្កើតឯកសារនេះ ...........៣

២.២ ការបាត់បង់នានានៅក្នុងពេលទុកដាក់ ...........៤

២.២.១ ការបាត់បង់ជាបរិមាណ ...........៤

២.២.២ ការបាត់បង់គុណភាព ...........៥

២.៣ ការគ្រប់គ្រងគ្រាប់ស្រូវនៅមុនពេលទុកដាក់ ...........៥

២.៣.១ ការប្រមូលផលក្នុងពេលដ៏ត្រឹមត្រូវ ...........៥

២.៣.២ ការបោកបែនជាបន្ទាន់ និង ពុំធ្វើអោយប៉ះទង្គិចខ្លាំង ...........៧

២.៣.៣ ការសម្អាតសមស្រប ...........៨

២.៣.៤ ការហាលសម្ងួត ...........៩

២.៣.៥ កំណជាញើស ...........៩

២.៣.៦ កិច្ចការពារទល់នឹងសត្វកណ្តុរ ...........១១

២.៤ ជម្រើស ឬ វិធីទុកដាក់បែបថ្មី ...........១៤

២.៤.១ ការទុកដាក់ជាគំនរ ឬ ដោយចាក់ធារ ...........១៤

ការសាងសង់ជង្រុក ឬ បរិក្ខារទុកដាក់ជាគំនរ ...........១៥

២.៤.២ ការទុកដាក់ក្នុងបាវ ...........១៩

២.៤.៣ ការទុកដាក់ក្នុងបរិក្ខារបិទជិត ...........២០

២.៥ ផលចំណេញអំពីការកែច្នៃ ............២៣

២.៦ ឥទ្ធិពលទៅលើបរិស្ថាន ............២៥

៣. គោលការណ៍ណែនាំក្នុងការផ្សព្វផ្សាយ ............២៦

៣.១ ផែនការការងារ ............២៦

៣.១.១ ការកំណត់តម្លៃដែលត្រូវចំណាយ ............២៦

៣.១.២ អ្នកគាំទ្រ ............២៦

៣.១.៣ យេនឌ័រ ............២៦

៣.២ វិធីសាស្ត្រផ្សព្វផ្សាយ ............២៧

៣.២.១ ការជ្រើសរើសទីកន្លែង ............២៧

៣.២.២ ការជ្រើសរើសកសិករ និង ការរៀបចំ ............២៧

៣.២.៣ ការរួមចំណែកពីសំណាក់កសិករ និង អ្នកគ្រប់គ្រងការទុកដាក់ស្រូវ ....២៨

៣.៣ ពិសោធន៍ និង ការអនុវត្តន៍បង្ហាញ ............២៨

៣.៣.១ ចំណងជើង ............២៨

៣.៣.២ ទីកន្លែង ............២៨

៣.៣.៣ គោលបំណង ............២៨

៣.៣.៤ វិធីសាស្ត្រ ............២៨

៣.៣.៥ ការស្រង់ និង វិភាគទិន្នន័យ ............២៩

៣.៣.៥.១ ការវាស់កំណត់ប្រចាំខែ ............២៩

៣.៣.៥.២ ការវាស់កំណត់នៅពេលចាប់ផ្តើម និង ពេលបញ្ចប់............២៩

៣.៣.៥.៣ ការវាស់កំណត់អត្រាសំណើម ............៣០

៣.៣.៥.៤ ការកំណត់ទូវអត្រាដំណុះគ្រាប់ ............៣០

៣.៣.៥.៥ ការវាស់កំណត់អត្រាអង្ករដើម ............៣១

៣.៣.៥.៦ ការវាស់កំណត់អត្រាសត្វល្អិត ............៣៣

៣.៣.៦ ការអនុវត្តន៍បង្ហាញ ............៣៣

៣.៣.៧ ការចំណាយ (ទៅតាមលទ្ធភាពជាក់ស្តែង) ............៣៣

៣.៣.៨ សកម្មភាពដែលគួរអនុវត្តនៅក្នុងអំឡុងពេលទុកដាក់ ............៣៣

៣.៣.៨.១ ការពិនិត្យមើលជង្រុក ឬ កន្លែងទុកដាក់ ............៣៣

ការខូចខាតជង្រុក ឬ កន្លែងទុកដាក់ ............៣៣

វត្តមាននៃសត្វកណ្ដុរ និង សត្វស្លាប ........... ៣៤
វត្តមាននៃសត្វល្អិត ........... ៣៤
ការដុះ ឬ ការកើតផ្សិត ........... ៣៥
ការខូចខាតដោយសារសំណើម ........... ៣៥
៣.៣.៨.២ ការយកសំណាក ........... ៣៥
សំណាកបឋម ........... ៣៦
សំណាកសមាស ........... ៣៦
សំណាកស្តង់ដារ ........... ៣៦
ចំនួនសំណាកបឋម ........... ៣៦
ចំណុចដែលត្រូវយកសំណាក ........... ៣៧
៣.៣.៨.៣ ការពិនិត្យគុណភាព ........... ៣៧
ការវាស់កំណត់អត្រាសំណើម ........... ៣៧
ការវាស់កំណត់សីតុណ្ហភាពគ្រាប់ស្រូវ ........... ៣៨
៣.៣.៨.៤ ការវាយតម្លៃអំពីការបាត់បង់ ........... ៣៨

## ១. ការពិពណ៌នា

### ១.១ គោលបំណង និង សារៈប្រយោជន៍

ដោយយល់ឃើញថា :

- ការកាត់បន្ថយនូវការបាត់បង់គ្រាប់ស្រូវនៅក្រោយពេលប្រមូលផលគឺជាមធ្យោបាយ ឬ វិធីដ៏មានប្រសិទ្ធិភាពក្នុងការកាត់បន្ថយនូវទំហំដីស្រែចម្ការដែលត្រូវការសម្រាប់ការដាំដុះ និង ក្នុងការបង្កើននូវស្បៀងអាហារ
- ផលវិបាកនៃការទុកដាក់ផលិតផលនេះមិនសមស្របនៅកម្ពុជាមានសភាពធ្ងន់ធ្ងរ ហើយ
- ការផ្សព្វផ្សាយនូវចំណេះដឹងស្តីអំពីបរិក្ខារ និង បច្ចេកទេសទុកដាក់សមស្របដល់កសិករនៅតែជាកិច្ចការយ៉ាងមានសារៈសំខាន់

ឯកសារនេះត្រូវបានរៀបចំឡើងដើម្បី :

- ចងក្រងនូវព័ត៌មានដែលមានលក្ខណៈទាក់ទងនានាស្តីអំពីបច្ចេកទេស និង បែបបទទាំងឡាយដែលមានប្រសិទ្ធភាព និង ងាយស្រួលក្នុងការអនុវត្តន៍ ក្នុងការទុកដាក់គ្រាប់ស្រូវ ដោយផ្អែកទៅលើកិច្ចអនុវត្តន៍ជាក់ស្តែង និង លទ្ធផលនៃការស្រាវជ្រាវថ្មីៗ
- ផ្តល់ដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មនូវគោលការណ៍ណែនាំ និង ជម្រើសបច្ចេកទេសទាំងឡាយដែលមានលក្ខណៈមិនស្មុគ្រស្មាញ ងាយស្រួលក្នុងការអនុវត្តន៍ និង ជ្រើសរើស តម្រូវទៅតាមលក្ខខ័ណ្ឌជាក់ស្តែង និង ធនធានដែលមាន ឬ អាចរកបានក្នុងការផ្ទេរនូវចំណេះដឹងដល់កសិករ និង អ្នកគ្រប់គ្រងស្រូវដើម្បីអោយគាត់អាចបង្កើនផលចំណេញ និង រក្សាបាននូវគុណភាពផលិតផល ។

### ១.២ លក្ខណៈវិនិច្ឆ័យអំពីភាពសមស្របខាងផ្នែកបច្ចេកទេស

ដោយយកចិត្តទុកដាក់ទៅលើលក្ខណៈវិនិច្ឆ័យនានាដូចដែលមានរៀបរាប់ខាងក្រោម នឹងធ្វើអោយប្រាកដថាអនុសាសន៍នានាក្នុងឯកសារនេះអាចនឹងអនុវត្តបានសមស្របទៅតាមសេចក្តីប្រាថ្នា :

#### ១.២.១ យេនឌ័រ

ការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចការនេះមានសារៈសំខាន់ជាទីបំផុត ។ ជាទូទៅ ស្ត្រីកម្ពុជាជាអ្នកធ្វើនូវកិច្ចការផ្ទះសម្បែងស្ទើរតែទាំងអស់ដោយរួមទាំងកិច្ចថែរក្សាកសិផលដែលប្រមូលបានដូចជាគ្រាប់ស្រូវជាដើម ។ ការផ្តល់ដល់ស្ត្រីនូវចំណេះដឹងស្តីពីបច្ចេកទេស និង វិធីទុកដាក់គ្រាប់ស្រូវ ព្រមទាំងកិច្ចការពារទប់ស្កាត់ចំពោះការបាត់បង់ដែលមានភាពសមស្របទៅតាមលក្ខណៈវិទ្យាសាស្ត្រ នឹងធ្វើអោយស្ត្រី និង ក្រុមគ្រួសារមានលទ្ធភាពយ៉ាងប្រាកដក្នុងការធ្វើអោយកាន់តែប្រសើរនូវសុវត្ថិភាពស្បៀង តាមរយៈការមានកាន់តែច្រើននូវបរិមាណស្រូវដែលប្រកបដោយគុណភាពខ្ពស់សម្រាប់ការហូបចុក ក៏ដូចជាសម្រាប់ការលក់ដូរ ។